# ស័ង្ខសិល្បជ័យ

ភាគទី៩

លុះរៀបចំរួចស្រេចហើយ ទ្រង់ក៏ក្រាបបង្គំយាងសម្តេចព្រះមាតុច្ឆាចូលព្រះនគរ។ កេសរសុមន្ទាស្តាប់ហើយឆ្លើយថា: "កូនអើយចិត្តមាតាមិនណាយបិតាកូននោះឡើយ តែថាមាតាមានបុត្រីដែលត្រូវជាប្អូនបុត្រ ឥឡូវត្រូវព្រាត់ទៅឆ្ងាយរហូតដល់ពិភពនាគ ដោយបុណ្យចេស្តារបស់បុត្រដូច្នេះសូមបុត្រទៅយកប្អូនមកមូលនឹងមាតាផង..."។ ព្រះពោធិសត្វទ្រង់សណ្តាប់រួចក៏ធានាថា នឹងទៅយកមកថ្វាយឲ្យបាន។ បន្ទាប់មកព្រះពោធិសត្វក៏នាំមាតុច្ឆាទៅគង់នៅប្រាសាទទិព្វ ដោយចំណីអាហារតាមតែចិត្តនឹក ទ្រង់ក៏ឲ្យរាជសីហ៍នៅចាំថែរក្សាព្រះមាតុច្ឆា ស្រេចហើយក៏ក្រាបបង្គំលាចេញទៅ។ ទ្រង់អធិដ្ឋានផ្សងនូវបារមីព្រះអង្គ ដែលអនាគតក្លាយជាព្រះពុទ្ធថា: "បើឋាននាគនៅត្រង់ណាសូមឲ្យស័ង្ខសិល្បជ័យនាំទៅទីនោះ"។ ផ្សងស្រេចទ្រង់ក៏ឡើងគង់លើស័ង្ខ ហើយស័ង្ខក៏នាំផ្លូវទៅដល់ឆ្នេរសមុទ្រ ស័ង្ខក៏មុជជ្រែកផ្ទៃទឹកនាំព្រះពោធិសត្វរហូតដល់ឋាននាគ។ ព្រះពោធិសត្វទ្រង់យាងមើលផ្សារតាមកន្លែងផ្សេងៗ រួចហើយក៏បបួលរាស្ត្រនាគលេងល្បែងបាសកា។ រាស្ត្រនាគទាំងអស់លេងជាមួយព្រះពោធិសត្វ គ្មាននរណាមួយយកឈ្នះបានឡើយ។ មិនយូរប៉ុន្មានក៏ឮល្បីដល់មន្ត្រីនាគ។ មន្ត្រីនាគក៏បានយាងព្រះពោធិសត្វទៅលេងបាសកា ហើយក៏ចាញ់ដៃព្រះពោធិសត្វ។ កាលនោះទ្រង់ក៏អួតអាងថា: "មិនថារាស្ត្រ ឬមន្ត្រីទេ គ្មាននាគណាមួយអាចឈ្នះលើយើងជាមនុស្សបានឡើយ"។ ក្នុងកាលនោះដែរ មន្ត្រីនាគក៏បាននាំពាក្យទៅទូល

អត្ថបទដោយ៖ មាស សុភាព

ស្ដេចនាគ។ ព្រះបាទកុជង្គនាគទ្រង់សណ្ដាប់រួចត្រាស់បញ្ជាថា: "ទៅអញ្ជើញព្រះថៅនោះមក លាភមកដល់ហើយ មនុស្សណាហ៊ានមកអួតលេងបាសកានឹងនាគនោះឃើញរាស្ត្រ និងមន្ត្រីនាគចាញ់ដៃនោះ ដោយសារពួកគេខ្ជីខ្ជាប៉ុណ្ណោះ ចំណែកយើងៗមានបុណ្យគ្មាននរណាមកលេងឈ្នះយើងឡើយ..."។ កាលនោះអាមាត្យទទួលរាជបញ្ជាហើយ ក៏ប្រញាប់រត់ទៅក្រាបបង្គំព្រះពោធិសត្វទូលថា: "បពិត្រព្រះមហាក្សត្រ ពេលនេះស្ដេចនាគ ទ្រង់យាងស្ដេចទៅ..."។ ព្រះពោធិសត្វពុំបានប្រណិប័តន៍ស្ដេចនាគទេ ទ្រង់គង់ស្ងៀមដោយមិនមានភ័យអ្វីឡើយ...។ ស្ដេចនាគទទួលហើយ ក៏បានសួរពីឈ្មោះ និងនគររបស់ព្រះពោធិសត្វ។ ព្រះពោធិសត្វសណ្ដាប់ហើយ ឆ្លើយថា: "ព្រះបិតាយើង ព្រះនាមសេនាកុត្តរាជសយរាជ្យនៅ ឧត្តរបញ្ចាល យើងជារាជបុត្រព្រះអង្គព្រះនាម ស័ង្ខសិល្បជ័យ"។

យើងមកឥឡូវ ប្រយោជន៍នានៅ លេងលងបាសកា
ភ្នាល់យកសម្បត្តិ រម្យរដ្ឋសីមា នូវអង្គព្រះមហា
មហេសីមិត្តផង។
ស្ដេចនាគទ្រង់សណ្ដាប់រួច ក៏ឆ្លើយថា:
ឯអង្គក្សត្រី រតន៍រាជមហេសី ពីរនឹងអាត្មា
នោះសូមពីមិត្ត ចេញឥតសង្កា រីរាជសីមា
ថ្វាយដោយចិត្តចង់។

នេះបើមិត្តឈ្នះបាសកាយើងៗ នឹងថ្វាយរាជសីមាដោយមិនប្រកែកឡើយ យើងសូមតែរាជទេពីចេញប៉ុណ្ណោះ តែថាបើមិត្តចាញ់ដៃវិញ តើបានអ្វីមកជាតំណាងបាសកា? ព្រះពោធិសត្វឆ្លើយ យើងមានធ្នូសិល្ប៍ ព្រះខ័នជ័យនិង

អត្ថបទដោយ៖ មាស សុភាព

ស័ង្ខ ទ្រព្យទាំងបីនេះ គឺមានតម្លៃឥតគូប្រៀប យើងសូមដាក់ជាតំណាង បើយើងចាញ់ដៃមិត្ត យើងនឹងប្រគល់ឲ្យដោយមិនប្រកែកឡើយ...។

ស្តេចនាគសួរវិញ មិត្តអើយមិត្តថា យកធ្នូសិល្ប៍ ព្រះខ័ន និងស័ង្ខជាតំណាងបាសកា តើសិល្ប៍នោះមានឫទ្ធិយ៉ាងណា?

ព្រះពោធិសត្វទ្រង់សណ្តាប់រួច ក៏ទ្រង់ថ្វៃងសរឡើងទៅលើអាកាសវេហាស៍ក្លាយជាប្រាសាទដ៏ស្អាតមួយ មានកិន្នរីរយ៉ាងល្វតល្វន់មើលទៅគួរឲ្យអស្ចារ្យណាស់។ ព្រះពោធិសត្វ ទ្រង់មានបន្ទូលថា: "មិត្តឃើញទេ នេះគ្រាន់តែធ្នូសិល្ប៍បន្តិចប៉ុណ្ណោះ ចំណែកស័ង្ខមានកំលាំងខ្លាំងមហិមា"។ ទ្រង់ក៏បោះឡើងទៅលើ បញ្ចេញទឹកប្រៀបបាននឹងភ្លៀង រួចហើយទ្រង់ក៏គ្រវីព្រះខ័នក្លាយជាអគ្គីឆាបឆេះសន្ធោសន្ធៅ។ លុះចប់ហើយ ទ្រង់ក៏សួរថា: "ដូចម្តេចហើយមិត្ត តើរបស់ទាំងបីនេះអាចតាំងតំណាងបាសកាបានទេ?"។ ព្រះបាទកុជង្គនាគទ្រង់តបវិញថា: "ធ្នូ សិល្ប៍ ព្រះខ័ន និងស័ង្ខសឹងជារបស់ប្រពៃណាស់អាចតាំងជាតំណាងបាន"។ រួចហើយ ទ្រង់ក៏ឲ្យអាមាត្យរៀបចំបាសកា។ បន្ទាប់មកក្សត្រទាំងពីរក៏លេងបាសកាយ៉ាងយកចិត្តទុកដាក់។ ទីបំផុតព្រះពោធិសត្វបានឈ្នះស្តេចនាគប្រាំពីរក្តារ ព្រះពោធិសត្វទ្រង់មានបន្ទូលថា: "យ៉ាងម៉េចហើយមិត្តពេលនេះយើងឈ្នះហើយ យើងមិនយកទេដែនដីសីមារបស់អ្នក យើងយកតែរាជទេពីទៅនគរវិញប៉ុណ្ណោះ"។

ស្តេចនាគឆ្លើយ យើងមិនឲ្យរាជទេពីទៅមិត្តបានទេ យើងបាននិយាយពីដើមមកថាបើមិត្តឈ្នះ មិត្តយកសីមាចុះ ត្រង់រាជទេពីនិងយើងសូមចុះចេញ។

ព្រះពោធិសត្វមានបន្ទូល យើងនឹងមកទៅឲ្យបាន ចូរមិត្តស្តាប់ណាយើងរ៉ាយរ៉ាប់ប្រាប់មិត្តថា ព្រះអង្គសេនាកុត្តរាជយើងមានអនុជក្សត្រីមួយអង្គព្រះ

នាមកេសរសុមន្ទាដែលកុម្ភ័ណ្ឌលួចយកមក ហើយក៏មានបុត្រីមួយអង្គនាមសុពណ៌ទេវីនេះ ត្រូវជាប្អូនស្រីយើង ដូច្នេះយើងត្រូវតែយកទៅវិញ ហើយបើចង់ច្បាំងគួរតែគិតឲ្យវែងអម្បាលកុម្ភ័ណ្ឌយក្សមានពលរាប់មិនអស់ គង់មិនជានាបាននឹងឫទ្ធិយើង ចំណែកស្ដេចនាគ យើងមិនភ័យព្រឺព្រួចអ្វីឡើយ...។ មានបន្ទូលតែប៉ុណ្ណោះ ទ្រង់ក៏ចូលទៅចាប់ដៃសុពណ៌ទេវីៗ ភ័យក៏ហៅស្ដេចនាគឲ្យជួយ។ ស្ដេចនាគឃើញដូច្នោះខឹងក្រោធយ៉ាងខ្លាំង ហៅអស់ពលយោធាសេនាមន្ត្រីមកដើម្បីតតាំងឫទ្ធិ។ ពួកពលនាគ សេនានាគមកចោមរោមព្រះពោធិសត្វ និងប្រែកាឡាគ្រប់រូបភាពមើលទៅគួរឲ្យខ្លាចណាស់ តែព្រះពោធិសត្វមិនភ័យខ្លាចអ្វីឡើយ ទ្រង់មានបន្ទូលថា: "តើមកជុំគ្នាហើយឬនៅនឹងអាលយើងថ្ងៃងសរកុំឲ្យសល់"។

ស្ដេចនាគឆ្លើយថា: "អ៊ើយមនុស្ស! កុំមកអួតអាង មិនដឹងឫទ្ធិយើង"។ ពោលហើយស្ដេចនាគ ក៏ថ្ងៃងសរទៅលើអាកាសក្លាយជាអាវុធជាច្រើនធ្លាក់ចុះមក ព្រះពោធិសត្វក៏ថ្ងៃងសរជាខ្យល់ផាត់ទៅអស់។ រួចហើយទ្រង់ក៏ថ្ងៃងសរជាគ្រុឌធំហោះមកចឹកនាគស៊ី។ សេនា មន្ត្រី ព្រមទាំងស្ដេចនាគទាំងអស់ភិតភ័យរត់គេចរកកន្លែងពួនគ្រប់គ្នាដោយខ្លាចបារមី ព្រះពោធិសត្វក៏បានឲ្យស័ង្ខដេញនាគចេញទាំងអស់ដោយផ្ដាំថា កុំសម្លាប់គ្រាន់តែបំភ័យឲ្យរាងចាលទៅបានហើយ...។ ក្នុងកាលនោះដែរ ទេពតាក៏បានថ្វាយព្រះពរសព្ទសាធុការដល់ព្រះពោធិសត្វ ហេតុព្រះអង្គទ្រង់ក៏បានត្រាស់ជាព្រះពុទ្ធនាអនាគត។

**(សូមដានរឿង ស័ង្ខសិល្បជ័យ ភាគទី១០ នៅសប្ដាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព